# Living the Lotus 3

## Buddhism in Everyday Life

2026
VOL. 246




## Thai and Cambodian Youth Pray for Peace amid Border Conflict on February 8, Joined by the Global Sangha of Rissho Kosei-kai


**Living the Lotus**
**Vol. 246 (March 2026)**

Senior Editor: Takashi Maeda
Editor: Sachi Mikawa
Copy Editor: Penn Setharin

*Living the Lotus* is published monthly
By Rissho Kosei-kai International,
Fumon Media Center, 2-7-1 Wada,
Suginami-ku, Tokyo 166-8537, Japan.
TEL: +81-3-5341-1124
FAX: +81-3-5341-1224
Email: living.the.lotus.rk-international@kosei-kai.or.jp


រីហ្សូកូសេកៃគឺជាអង្គការចលនាពុទ្ធសាសនាសកលមួយដែលមានពុទ្ធបរិស័ទ ជាច្រើនមានជំនឿលើគម្ពីព្រះសូត្រផ្កាឈូកសដែលជាព្រះសូត្ររបស់ព្រះពុទ្ធសាសនាមួយដ៏សំខាន់។ ពុទ្ធបរិស័ទទាំងនោះ បានខិតខំអនុវត្តការបង្រៀន របស់ព្រះបរមគ្រូនៃយើងទៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃដូចជា នៅកន្លែងការ ងារឬនៅក្នុងក្រុមគ្រួសាររបស់ពួកគាត់ជាដើម។ជាពិសេសគឺខំប្រឹងអនុវត្តធ្វើយ៉ាងណាអោយពិភពលោកទទួលបានសុខសន្តិភាព។
អង្គការរីហ្សូកូសេកៃ ត្រូវបានបង្កើតឡើងនៅឆ្នាំ 1983 ដោយ ស្ថាបនិក Nikkyo Niwano (1906-1999) និង, សហស្ថាបនាយិកា Myoko Naganuma (1889-1957) បច្ចុប្បន្នក្រោមការណែនាំពីលោកប្រធាន Nichiko Niwano សមាជិក រីហ្សូកូ សេកៃទាំងអស់ក្នុងនាមជាពុទ្ធបរិស័ទបានកំពុងប្រឹងប្រែងយ៉ាងសកម្មក្នុងការចែករំលែកព្រះធម៌និងចូលរួមសកម្មភាពសន្តិភាពទាំងក្នុងនិងក្រៅប្រទេសក្នុងកិច្ចសហការជាមួយមនុស្សគ្រប់មជ្ឈដ្ឋាន។

The title of this newsletter, *Living the Lotus—Buddhism in Everyday Life*, conveys our hope of striving to practice the teachings of the Lotus Sutra in daily life in an imperfect world to enrich and make our lives more worthwhile, like beautiful lotus flowers blooming in a muddy pond. This newsletter aims to help people around the world apply Buddhism more easily in their daily lives.

会長法話

# ពិចារណាល្អិតល្អន់ទៅលើ "ភាពតែមួយ"

庭野日鑛
立正佼成会会長



## ទស្សនៈរបស់ព្រះធម៌បទុមសូត្រទៅលើមនុស្សជាតិ និងពិភពលោក

មកដល់ថ្ងៃនេះនរណាក៏គេដឹងដែរថាយើងទាំងឡាយដែលជាសមាជិកនៃអង្គការរីស្សូកូសេកៃជ្រកកោនពឹងពាក់អាស្រ័យទៅលើគម្ពីរសាសនាមហាយាន«ព្រះត្រៃបទុមសូត្រ» (ព្រះអនន្តនិទ្ទេសសូត្រ ព្រះសទ្ធបុណ្ឌរិកសូត្រ ឬព្រះបទុមសូត្រនិងវិធីសាស្ត្រពិចារណានៃព្រះពោធិសត្វសមន្តភទ្រសូត្រ)ជាពិសេសយើងផ្តល់តម្លៃខ្ពស់ទៅលើទស្សនៈគោរពមាគ៌ានៃមនុស្សជាតិនិងពិភពលោកដែលបង្ហាញឡើងនៅក្នុងព្រះសទ្ធបុណ្ឌរិកសូត្រឬព្រះបទុមសូត្រ ។

ទស្សនៈមនុស្សជាតិនោះគឺសេចក្តីប្រាថ្នា បង្កើនសេចក្តីសុខនិងកាត់បន្ថយទុក្ខនៃអ្នកដែលនៅជុំវិញខ្លួនដែលចាប់ផ្តើមពីចិត្តមេត្តាករុណាហើយអនុវត្តពោលគឺធ្វើកិច្ចប្រតិបត្តិព្រះពោធិសត្វ។ ទស្សនៈពិភពលោករបស់ព្រះបទុមសូត្របង្រៀនថាប្រសិនបើមនុស្សគ្រប់គ្នាចាប់ភ្លឹកថាខ្លួនជាព្រះពោធិសត្វហើយម្នាក់ៗដឹងនិងបង្ហាញធាតុព្រះពុទ្ធព្រមទាំងខិតខំអភិវឌ្ឍធាតុព្រះពុទ្ធនោះពិភពលោកនេះ (ពិភពសាហា) - នឹងទៅជាសុខាវតីពោលគឺពិភពសុខក្សេមក្សាន្តប្រកបដោយពន្លឺជាក់ជាមិនខាន។

ម្យ៉ាងទៀតខ្ញុំព្រះករុណាអាត្មាភាពយល់ថា ព្រះធម៌បទុមសូត្របង្រៀនយើងថាបញ្ហាដែលយើងឃើញនិងឮសព្វថ្ងៃនេះរាប់តាំងពីបញ្ហាពិភពលោករហូតដល់បញ្ហាតូចតាចដែលកើតមាននៅក្បែរៗខ្លួនយើង មិនអាចដោះស្រាយបានដោយនរណាផ្សេងម្នាក់ឬក៏អ្វីមួយក្រៅពីយើងខ្លួនយើងម្នាក់ៗព្យាយាមដើរតាមមាគ៌ាត្រឹមត្រូវមិនផ្លាតជើងពីសម្មាមាគ៌ាដែលជាសេចក្តីបង្រៀនប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធហើយងើបឈរត្រង់ដូចរុក្ខជាតិដែលផុសចេញពីព្រះធរណីនោះទេ។

នេះអាចគ្រាន់តែជាការបកស្រាយលំៗមិនលំអិតទេក៏មិនដឹងគឺថាព្រះធម៌បទុមសូត្របង្ហាញទៅកាន់មនុស្សទាំងឡាយថា" មនុស្សសាមញ្ញដែលគ្មានឈ្មោះបោះសម្លេងដូចពួកយើងក៏មានសមត្ថភាពនិងមានទំនួលខុសត្រូវក្នុងការដោះស្រាយបញ្ហាជីវិតមនុស្សនិងបញ្ហាពិភពលោកដែរ"ហើយលើកទឹកចិត្តឱ្យដឹងខ្លួនឯងថាយើងម្នាក់ៗជាព្រះពោធិសត្វ។គំនិតនេះគាំទ្រដោយគំនិតស្នូលនៃព្រះធម៌បទុមសូត្រនៅចំណុចថា "ជីវិតទាំងអស់ត្រូវបានពង្រស់ដោយជីវិតដ៏អស្ចារ្យតែមួយគត់" និង "អ្វីៗគ្រប់យ៉ាងគឺតែមួយ" ។

## ចក្រវាលគឺតែមួយ ពិភពលោកក៏គឺតែមួយ

ស្ថាបនិកកៃស្វូសាម៉ារបស់យើងធ្លាប់បានមានសង្ឃដីកាថា"អាត្មាភាពបង្កើតអង្គការនេះក្នុងគោលបំណងតែមួយគឺដើម្បីជួយសង្គ្រោះមនុស្ស"។

ហេតុអ្វីបានជាទើបតែឥឡូវនេះបានខ្ញុំព្រះករុណាអាត្មាភាពលើកយកព្រះធម៌បទុមសូត្រមកពន្យល់បកស្រាយអីចឹង ? គឺដើម្បីឱ្យយើងទាំងអស់គ្នារំលឹកឃើញមូលដ្ឋានគ្រឹះដែលឆ្លុះបញ្ចាំងពីស្មារតីនៃអង្គការរបស់យើងនិងឆ្លាក់ទុកនៅក្នុងចិត្តរបស់យើងនូវគំនិតសំខាន់ថា "អ្វីគ្រប់យ៉ាងគឺតែមួយ" ដែលដើរតួជាកម្លាំងជំរុញនៅពីក្រោយដំណើរក្នុងការជួយសង្គ្រោះមនុស្សរបស់យើង ។

"អ្វីគ្រប់យ៉ាងគឺតែមួយ" ។ នេះជាការពិតណាស់គំនិតមួយដែលផ្អែកទៅលើការបង្រៀ នប្រៀនប្រដៅនៃយានមួយរបស់ព្រះធម៌បទុមសូត្រ។ បើនិយាយឱ្យសាមញ្ញទៅ មានន័យថា "ចក្រវាលគឺតែមួយ ផែនដីគឺតែមួយ ហើយពិភពលោកគឺតែមួយ"។

ផែនដីបានកើតមកនៅពេលដែលចក្រវាលបានវិវត្តទៅជាតែមួយដូចជាជីវិតតែមួយដែលវិវត្តទៅជាតែមួយរួចហើយនៅលើផែនដីនេះ អ្វីៗទាំងអស់ជួយគ្នាទៅវិញទៅមកពង្រស់គ្នាទៅវិញទៅមកដើម្បីរស់។ ហើយការពិតយើងអាចនិយាយថាវាមានន័យថាចក្រវាលទាំង មូលគឺជា មហាជីវិត មួយហើយបង្ហាញថាជីវិតយើងម្នាក់ៗក៏សុទ្ធតែបង្រួមទៅជាមួយ ផ្ជាប់ទៅជាមួយនឹងអ្វីៗទាំងអស់។

នៅក្នុងពិភពនៃសាសនាគេបង្រៀនថា អ្វីដែលសាសនាជាច្រើនមានរួមគ្នា គឺការរួបរួមនៃអ្វីៗទាំងអស់ឱ្យទៅជាមួយ និងស្មារតីនៃ "មេត្តា" និង "សេចក្តីស្រឡាញ់" ។ ហើយសំខាន់ជាងនេះទៅទៀត យើងទាំងអស់គ្នាគឺជា "តែមួយ" នៅក្នុងអារម្មណ៍នៃការគោរពបូជាចំពោះព្រះ និងព្រះពុទ្ធ។ ហេតុដូច្នេះហើយ មិនត្រឹមតែអ្នកកាន់សាសនាទេប៉ុន្តែមនុស្សគ្រប់រូប មិនត្រូវគិតតែពីចាក់ចុចគ្នាដោយសារតែបញ្ហាល្អិតល្អោចរបស់គ្នាទៅវិញទៅមកទេ ផ្ទុយទៅវិញ ត្រូវផ្តោតទៅលើចំណុចរួមរវាងខ្លួនយើង និងអ្នកដទៃ ហើយទទួលស្គាល់ថាយើងទាំងអស់គ្នាគឺជា "តែមួយ"។ពេលនោះ ស្មារតីនៃសេចក្តីមេត្តា និងការអត់ឱនដ៏ជ្រាលជ្រៅនឹងកើតឡើងនៅក្នុងចិត្តរបស់យើងម្នាក់ៗ។

ពិភពនៃ "សេចក្តីសង្គ្រោះ" ដែលជាកន្លែងផ្តល់សន្តិភាពនិងសេចក្តីសង្ឃឹមដើម្បីរស់នឹងលាតសន្ធឹងធំទៅៗជាប្រាកដ ក៏ប៉ុន្តែធម្មជាតិរបស់មនុស្សធ្វើឱ្យអ្វីទាំងនេះមិនអាចទៅរួច។

ឆ្លើយតបនឹងបញ្ហានេះ ស្ថាបនិកកៃស្វូសាម៉ាបានមានសង្ឃដីកាថា "មនុស្សម្នាក់ៗមានអត្តចរិតផ្ទាល់ខ្លួនឋានៈឬតួនាទីរបស់គេនិងបញ្ហាឬកាលៈទេសៈរបស់គេ។ ប្រសិនបើអ្នកយល់ពីចំណុចទាំងនេះ ចិត្តសប្បុរសទៅលើគ្នាទៅវិញទៅមកនឹងកើតឡើងដោយធម្មជាតិ"។នៅសមាជពិភពលោកលើកទី៣នៃសាសនាដើម្បីសន្តិភាព (1979) ស្ថាបនិកកៃស្វូសាម៉ាបានថ្លែងសារដោយក្តីបារម្ភហាក់ដូចជាកំពុងប្រ មើលឃើញស្ថានភាពបច្ចុប្បន្ននៃពិភពលោកនិងផែនដីថា"បច្ចុប្បន្នកាលនេះច្បាស់ណាស់ថាពិភពលោកត្រូវតែ ទៅឱ្យរំលងហួសពីជាតិនិយមចង្អៀតចង្អល់ហើយឆ្ពោះទៅរកតំបន់និយមរួចហើយទីបំផុតឆ្ពោះទៅរកសកលលោកនិយមទើបបាន"។

ចាប់តាំងពីពេលនោះមកដល់សព្វថ្ងៃមានរយៈពេលជិតកន្លះសតវត្សទៅហើយខ្ញុំព្រះករុណាអាត្មាភាពនៅតែមានអារម្មណ៍សោកស្តាយដែលស្មារតីនៃ "ការសង្គ្រោះមនុស្ស" របស់អង្គការយើងមិនទាន់សម្រេចបានពេញលេញនៅឡើយហើយខ្ញុំព្រះករុណាអាត្មាភាពចង់ឆ្លុះបញ្ចាំងម្តងទៀតអំពីបេសកកម្មរបស់យើងក្នុងការកសាងពិភពលោកឱ្យទៅជា "មួយ" និងជួយគ្នាទៅវិញទៅមក។

មក។

កាសែតកូសេ ខែមីនា ឆ្នាំ២០២៦

# Rissho Kosei-kai International

## Make Every Encounter Matter



## A Global Buddhist Movement




Information about local Dharma centers

facebook

X

We welcome comments on our newsletter Living the Lotus: living.the.lotus.rk-international@kosei-kai.or.jp